ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៥-០១៨-០០២ ណ.ភ.ណ.ន

ថ្ងៃសុក្រ ៦រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៨

# សេចក្តីណែនាំ
# លើការអនុវត្តប្រតិបត្តិការ
# ផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)

យោងសេចក្តីជូនដំណឹងលេខ ធ១.០១១៦.០៥៤.ពិសេស ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការដាក់ឲ្យអនុវត្តប្រតិបត្តិការ LPCO ធនាគារជាតិនៃកម្ពុជាសូមជម្រាបជូនគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់អំពីលក្ខខ័ណ្ឌចាំបាច់ និងនីតិវិធីមួយចំនួនក្នុងការចូលរួមដេញថ្លៃប្រតិបត្តិការ LPCO ដូចតទៅ៖

**ក- លក្ខខ័ណ្ឌចាំបាច់មុនពេលដេញថ្លៃ**

- ត្រូវចុះកិច្ចសន្យាជាមួយធនាគារជាតិនៃកម្ពុជា លើកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញរបស់ធនាគារជាតិនៃកម្ពុជា។
- ត្រូវដាក់ពាក្យស្នើសុំប្រើប្រាស់ផ្ទៃតហ្វមធនាគារជាតិនៃកម្ពុជា (NBCP)។
- ត្រៀមបម្រុងមូលបត្រអាចជួញដូរបាន (NCD) សម្រាប់ធានាប្រតិបត្តិការ LPCO ដែលទទួលបានជោគជ័យក្នុងការដេញថ្លៃ។ ធនាគារជាតិនៃកម្ពុជានឹងចេញផ្សាយ NCD នៅរៀងរាល់ថ្ងៃព្រហស្បតិ៍បន្ទាប់ពីទទួលបានពាក្យសុំជាវនៅថ្ងៃពុធ។
- តណប្រតិទានរបស់ NCD ត្រូវតែធំជាង ឬស្មើនឹងតណប្រតិទានរបស់ប្រតិបត្តិការ LPCO។ NCD ជាប្រាក់ដុល្លារអាមេរិកដែលបានដាក់ធានា នឹងត្រូវអនុវត្ត Haircut លើតម្លៃចារឹក ក្នុងកម្រិតមួយដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

**ខ- នីតិវិធីក្នុងការដាក់ដេញថ្លៃ**

- ទំហំទឹកប្រាក់ដាក់ឱ្យដេញថ្លៃមួយលើកៗ នឹងត្រូវបានជូនដំណឹងមួយសប្តាហ៍មុនថ្ងៃដេញថ្លៃ
- ទំហំទឹកប្រាក់ដេញថ្លៃអតិបរមា/អប្បបរមាក្នុងមួយគ្រឹះស្ថាន កម្រិត Haircut លើ NCD ជាប្រាក់ដុល្លារអាមេរិកដែលដាក់ធានា អត្រាការប្រាក់សម្រាប់តណប្រតិទាននីមួយៗ ព្រមទាំងនីតិវិធីដទៃទៀតពាក់ព័ន្ធនឹងការដាក់ដេញថ្លៃ នឹងត្រូវបានជូនដំណឹងនៅវេលាម៉ោង ៨:០០នាទីព្រឹកនៃថ្ងៃដេញថ្លៃ។
- ការដាក់ដេញថ្លៃត្រូវធ្វើឡើងតាមប្រព័ន្ធ NBCP ចាប់ពីម៉ោង ៨:០០នាទីព្រឹក រហូតដល់ម៉ោង ១២:០០ ថ្ងៃត្រង់។ ក្នុងករណីប្រព័ន្ធ NBCP មិនអាចអនុវត្តបាន ការដាក់ដេញថ្លៃត្រូវធ្វើតាម



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

សារអេឡិចត្រូនិក bod_lpco@nbc.org.kh ឬដាក់ក្នុងស្រោមសំបុត្របិទជិត ហើយផ្ញើទៅនាយកដ្ឋានប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជា។

- លទ្ធផលនៃការដេញថ្លៃនឹងប្រកាសនៅម៉ោង ២:០០នាទី រសៀល នាថ្ងៃដេញថ្លៃ។
- គ្រឹះស្ថានដែលដាក់ដេញថ្លៃតាមប្រព័ន្ធ NBCP ហើយទទួលជោគជ័យ នឹងទទួលបានលិខិតបញ្ជាក់លទ្ធផលនៃការដេញថ្លៃព្រមទាំងព័ត៌មានពាក់ព័ន្ធពីប្រព័ន្ធ NBCP ចំណែកគ្រឹះស្ថានដែលដាក់ដេញថ្លៃតាមសារអេឡិចត្រូនិក ឬតាមស្រោមសំបុត្រ ត្រូវចុះកិច្ចសន្យាបំពេញបន្ថែមជាមួយធនាគារជាតិនៃកម្ពុជា។
- នៅថ្ងៃទូទាត់ (២ថ្ងៃបន្ទាប់ពីថ្ងៃដេញថ្លៃ) គ្រឹះស្ថានដែលទទួលជោគជ័យក្នុងការដេញថ្លៃនឹងទទួលបានសន្ទនីយភាព បន្ទាប់ពីបានចុះកិច្ចសន្យាប្រគល់សិទ្ធិកាន់កាប់ NCD ជូនធនាគារជាតិនៃកម្ពុជា។ ក្នុងករណីមិនបានប្រគល់ NCD តាមកាលកំណត់ លទ្ធផលដេញថ្លៃដែលទទួលជោគជ័យនឹងត្រូវទុកជាមោឃៈ។
- នៅតណប្រតិទាននៃប្រតិបត្តិការ LPCO ធនាគារជាតិនៃកម្ពុជានឹងផ្ទេរសិទ្ធិកាន់កាប់ NCD ជូនភាគីខ្ចីប្រាក់វិញ បន្ទាប់ពីភាគីនេះបានទូទាត់ចប់សព្វគ្រប់នូវទឹកប្រាក់បានខ្ចី និងការប្រាក់ រួមទាំងកាតព្វកិច្ចផ្សេងៗទៀត ប្រសិនបើមាន។
- ការប្រាក់បង្គរនឹងត្រូវបានគណនាអាស្រ័យលើទំហំប្រាក់ រយៈពេលខ្ចីប្រាក់ អត្រាការប្រាក់ និងលើមូលដ្ឋានចំនួនថ្ងៃជាក់ស្តែងក្នុងឆ្នាំនីមួយៗ។

សេចក្តីណែនាំការអនុវត្តប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា លេខ ធ៥.០១៦.០០៥ ស.ក.ណ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ ត្រូវចាត់ទុកជាមោឃៈចាប់ពីថ្ងៃចេញសេចក្តីណែនាំនេះតទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុជ្រាប និងសហការអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់។

សូមទំនាក់ទំនងៈ
-ធនាគារជាតិនៃកម្ពុជា
-អគ្គនាយកដ្ឋានបច្ចេកទេស
-នាយកដ្ឋានប្រតិបត្តិការ
-លេខទូរស័ព្ទ: (៨៥៥-២៣) ៧២៤ ៩៦៣
(៨៥៥-២៣) ៧២២ ២២១ EXT. ១០៤៨
-សារអេឡិចត្រូនិក : lpco_info@nbc.org.kh